# ការអនុវត្តជាក់ស្តែងអំពីសន្តិកម្ម– ការរៀបចំបែងចែកសន្តិកម្ម

# នៅពេលទទួលបានរឿងក្តីសន្តតិកម្ម យើងគួរធ្វើបែបណា?


**YABUKI Kimitoshi**

Japan Federal Bar Associations

Committee on International Relations

# (1)អត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍ និង ការបញ្ជាក់អំពីខ្លឹមសារ

Rule

ការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍៖ សន្តតិកម្មមានសន្តតិកម្មតាមមតកសាសន៍របស់មតកជន និង សន្តតិកម្មតាមច្បាប់ ប៉ុន្តែ ប្រសិនបើមានមតកសាសន៍ មតកសាន៍នោះមានអាទិភាពជាង។ ហេតុនេះ យើងត្រូវបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍។ ព្រមទាំងត្រូវបញ្ជាក់ថា តើមតកសាសន៍នោះជាមតកសាសន៍ដែលបានបង្កើតឡើងដោយផ្អែកតាមឆន្ទៈរបស់មតកជនដែរឬទេ? ហើយត្រូវបញ្ជាក់ថាមតកសាសន៍នោះបានគោរពតាមទម្រង់នៃមតកសាសន៍ដែរឬទេ?

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្ដែង (1)
# ( បញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍ )

① មតកសាសន៍ដោយលិខិតយថាភូត(ម១១៧៣)

ក្នុងករណីមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត សារការីបានរក្សាទុកច្បាប់ដើម ហើយថែមទាំងមានសាក្សីចូលរួមទៀតផង ហេតុនេះ ការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាន៍មិនមានភាពលំបាកនោះទេ។

② មតកសាសន៍ដោយលិខិតសម្ងាត់(ម១១៧៥)

ដូចខាងលើ។ ហើយមាននៅសល់ច្បាប់ដើមជាមួយសារការី។

③ មតកសាសន៍ដោយលិខិតឯកជន(ម១១៧៤)

មតកសាសន៍ដោយលិខិតឯកជន ធ្វើឡើងដោយ ម្ចាស់បណ្ដាំសរសេរដោយខ្លួនឯងនិងចុះហត្ថលេខា ដោយមិនមានការចូលរួមពីសារការីផង និង សាក្សីផង ហេតុនេះមានករណីខ្លះ ការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍អាចមានភាពលំបាក។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង (1)
# ( បញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃមតកសាសន៍ )

⇒ ហេតុនេះ យើងអាចត្រូវស្រាវជ្រាវឯកសាររបស់មតកជន សាកសួរពត៌មានពីជនដែលត្រូវសន្មថាជាសន្តតិជន ចុះជួបមន្ទីរសារការី និងចុះជួបមេធាវីដែលអាចក្លាយជាអ្នកប្រតិបត្តិមតកសាន៍ ជាអាទិ៍ ប៉ុន្តែ ក្នុងករណីមតកសាសន៍ក្នុងចំណុចទី③នេះ ការស្រាវជ្រាវឯកសាររបស់មតកជន និងការសាកសួរពត៌មានពីជនដែលត្រូវសន្មតថាជាសន្តតិជនគឺជា វិធីសាស្រ្តចម្បង។

⇒ ក្នុងករណីដែលមិនច្បាស់ថាមាន ឬ គ្មានមតកសាសន៍ទេ យើងគួរសាកល្បងពិភាក្សាបែងចែកមត៌ក (ម១២៦៦)។ ក្នុងករណីមិនអាចពិភាក្សាបែងចែកបាននោះទេ នោះត្រូវបែងចែកតាមផ្លូវតុលាការ(ម១២៧០) ហើយមានលទ្ធភាពខ្ពស់ដែលយើងអាចដឹងច្បាស់ថាមាន ឬ គ្មានមតកសាសន៍ នៅក្នុងនីតិវិធីដែលធ្វើតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(2) (ភាពត្រឹមត្រូវនៃមតកសាសន៍)

- តើយើងអាចបញ្ជាក់ពីភាពត្រឹមត្រូវនៃមតកសាសន៍ដោយរបៀបណា? ជាពិសេស ក្នុងករណីមតកសាសន៍ដោយលិខិតឯកជន?

⇒ មតកសាសន៍ដោយលិខិតយថាភូត និង មតកសាសន៍ដោយលិខិតសម្ងាត់ គឺមានការចូលរួមពីសារការី និង សាក្សី ហេតុនេះ ចំពោះវិវាទអំពីភាពត្រឹមត្រូវនៃលិខិតប្រហែលជាមានតិចតួចប៉ុណ្ណោះ ប៉ុន្តែ មតកសាសន៍ដោយលិខិតឯកជនមិនមានការចូលរួមពីតតិយជនអព្យាក្រឹត្យណាមួយនោះទេ ហេតុនេះវិវាទអំពីភាពត្រឹមត្រូវនៃលិខិតនោះអាចកើតមានឡើង។ សរសេរដោយខ្លួនឯង និង ការធ្វើកោសល្យវិច័យការសរសេរ។ ហើយ ភាពចាំបាច់នៃទម្រង់មតកសាសន៍ក៏អាចធ្វើឲ្យមានវិវាទផងដែរ។ អាចប្តឹងតាមនីតិវិធីរដ្ឋប្បវេណី ( ក្រ/ណី ម១១៧០ ជាដើម)។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(3) (មតកសាសន៍ច្រើន)

- ក្នុងករណីមតកសាសន៍ដែលមានសុពលភាពមានច្រើន នោះវិវាទអាចកើតមានឡើង ថាតើគួរអនុវត្តមតកសាសន៍មួយណា។

⇒ មាត្រា ១១៨៩ បញ្ញត្តអំពី ការលុបចោលដោយទម្រង់មតកសាសន៍។

(ករណីសិក្សា)នៅក្នុងមតកសាសន៍ដោយលិខិតយថាភូត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ បានកំណត់ឲ្យ A ទទួលសន្តតិកម្មទ្រព្យសម្បត្តិទាំងអស់ ប៉ុន្តែ មតកសាសន៍ដោយលិខិតឯកជនចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ បានកំណត់ឲ្យ A ទទួលសន្តតិកម្មលើដីមួយកន្លែង ហើយ B ទទួលសន្តតិកម្មលើប្រាក់សន្សំក្នុងកុងធនាគារមួយចំនួន និង C ទទួលសន្តតិកម្មចំពោះទ្រព្យសម្បត្តិដែលនៅសល់ផ្សេងទៀត។ តើមតកសាសន៍មួយណាត្រូវយកមកអនុវត្ត ហើយត្រូវយកមកអនុវត្តដូចម្តេច?

# (2) ការកំណត់សន្តតិជន

Rule

ការបែងចែកមត៌កដោយរួមបញ្ចូលទាំងជនដែលគ្មានលក្ខណសម្បត្តិជាសន្តតិជនទៅក្នុងចំណោមសន្តតិជនត្រូវមោឃភាព ហើយការបែងចែកមត៌កតាមការពិភាក្សាដោយដកជនដែលមានលក្ខណៈសម្បត្តិជាសន្តតិជនមួយចំនួនចេញ ក៏ត្រូវមោឃភាពដែរ។ មានន័យថា ការកំណត់សន្តតិជនជាមុនមានភាពចាំបាច់មុននីតិវិធីសន្តតិកម្ម។

ក្នុងករណីការទទួលស្គាល់ក្រោយមរណភាពត្រូវអនុវត្តតាមមាត្រា១២៧៤។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្ដែង (1) (ការស្រាវជ្រាវ និង ការគ្រប់គ្រងសន្តតិជន)

- ក្នុងករណីដែលមិនដឹងអំពីសន្តតិជន តើយើងត្រូវស្រាវជ្រាវដោយវិធីណា?

⇒ ស្រាវជ្រាវពីទំនាក់ទំនងនៃអត្តសញ្ញាណរបស់មតកជនចាប់ពីពេលចាប់កំណើតរហូតដល់ពេលទទួលមរណភាព និង បង្កើតតារាងទំនាក់ទំនងសន្តតិកម្ម។

- សាកសួរពត៌មានពីកូនក្តី
- ប្រមូលឯកសារបញ្ជាក់ពីអត្តសញ្ញាណ (ឯកសារទាក់ទងទៅនឹងអត្រានុកូលដ្ឋាន ជាអាទិ៍)
- សាកសួរពត៌មានពីសហព័ទ្ធរបស់មតកជន ញាតិលោហិតខ្សែផ្ទាល់ និងបងប្អូនប្រុសស្រីជាអាទិ៍
- បញ្ញត្តិពិសេសស្តីពីទារកក្នុងគភ៌ (ម១១៤៩ ក២)

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(2)
# (ការកំណត់សន្តតិជន - ការកំណត់ជនដែលមានលក្ខណៈសម្បត្តិ)

- ទោះបីជាដឹងច្បាស់ថាមានសន្តតិជនដែលត្រូវបានកំណត់ក៏ដោយ ក៏ជនទាំងនោះមិនអាចក្លាយជាសន្តតិជនបានដែរ បើសិនជាសន្តតិជននោះបានទទួលមរណភាព (ម១១៤៩ ក១) ជាអភ័ព្វបុគ្គល (ម១១៥0) ឬ ការផ្តាច់មត៌កពីសន្តតិជន (ម១១៥១) ហេតុនេះ យើងត្រូវបញ្ជាក់អំពីចំណុចទាំងនេះ។
  - ក្នុងករណីមរណភាពព្រមពេលជាមួយគ្នា
  - អភ័ព្វបុគ្គល
  - ការផ្តាច់មត៌ក–បញ្ជាក់ពីភាពមាន ឬ គ្មានដោយតុលាការ(ម១១៥១ ក២)

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(3) (ក្នុងករណីសន្តតិជនជាជនបរទេស)

- តើសន្តតិជនបរទេស អាចទទួលសន្តតិកម្មលើមត៌កដែលមានរួមទាំងអចលនវត្ថុដែរឬទេ?

⇒ មិនអាចធ្វើលទ្ធកម្មដោយសន្តតិកម្ម ឬ អច្ច័យទានលើដីបាននោះទេ បើសិនគ្មានសញ្ជាតិកម្ពុជា (ម១១៥៥ ក១)

# (3) ការបញ្ជាក់ពីមត៌ក

Rule

នៅពេលទទួលរឿងក្ដីសន្តតិកម្ម តើយើងគួរគ្រប់គ្រងទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មដោយរបៀបណានោះ ក៏ជាបញ្ហាផងដែរ។ ក្នុងករណីដែលបែងចែកមត៌កដោយរួមបញ្ចូលទាំងទ្រព្យដែលមិនមែនជាមត៌ក នោះការពិភាក្សាបែងចែកទាំងមូលអាចក្លាយជាមោឃភាពដោយសារការភាន់ច្រឡំ ។ បើមានមត៌កមួយផ្នែកមិនបានបញ្ចូល នោះការបែងចែកមត៌កត្រូវធ្វើសាជាថ្មីក៏មាន។ ហើយមានករណីខ្លះមានវិវាទនៅតុលាការ ដោយសារតែសន្តតិជនបានអះអាងអំពីមត៌កថាជាទ្រព្យសម្បត្តិឯកជនរបស់ខ្លួនជាអាទិ៍។ ហើយក្នុងករណីដែលមើលឃើញច្បាស់ថាកាតព្វកិច្ចមានច្រើនជាងទ្រព្យសកម្ម នោះយើងអាចធ្វើនីតិវិធីបោះបង់សន្តតិកម្មភ្លាមៗ (ម១២៦០) ឬ ការយល់ព្រមដោយមានកម្រិត (ម១២៥៦) (ជាគោលការណ៍អំឡុងពេលនៃការយល់ព្រម ឬការបោះបង់ គឺមានរយៈពេល៣ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម -ម១២៤៨ ក១)។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(1) (ការគ្រប់គ្រងទ្រព្យសន្តតិកម្ម)

- តើយើងត្រូវជ្រើសយកវិធីណា ដើម្បីគ្រប់គ្រងទ្រព្យសន្តតិកម្ម ?

⇒ សាកសួរពត៌មានពីកូនក្តី

→ មានករណីជាច្រើនដែលកូនក្តីមិនសូវចាំច្បាស់នោះទេ។ ហេតុនេះ យើងត្រូវបង្ហាញឯកសារនានាឲ្យទៅកូនក្តីមើលដើម្បីរំលឹកការចងចាំឡើងវិញ និងរៀបចំជាតារាងពេលវេលាជាដើម។ បើមានភាពចាំបាច់យើងអាចថតសម្លេងអំពីការសាកសួរព៌តមានកូនក្តី។

⇒ ប្រមូលភស្តុតាងនានា

→ ប័ណ្ណកម្មសិទ្ធិអចលនវត្ថុ ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជី ឯកសារឆ្លើយឆ្លងដែលមតកជនរក្សាទុក លិខិតកិច្ចសន្យា សៀវភៅសរសេរ សៀវភៅកំណត់ហេតុ

- អចលនវត្ថុ : រកឃើញអចលនវត្ថុជាផលប្រយោជន៍ពិសេស
- ប្រាក់ក្នុងកុង : លិខិតបញ្ជាក់ប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ការកម្មង់ទិញសារជាថ្មីចំពោះលិខិតបញ្ជាក់ពីប្រតិបត្តិការពាណិជ្ជកម្មជាអាទិ៍

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង (2) (ការគ្រប់គ្រងតម្លៃទ្រព្យសន្តិកម្ម)

- ទោះបីជាគ្រប់គ្រងទ្រព្យសន្តិកម្មបានក៏ដោយ យើងត្រូវវាយតម្លៃលើទ្រព្យនោះផងដែរ។

⇒ អចលនវត្ថុ : តើត្រូវវាយតម្លៃអចលនវត្ថុនោះឬទេ? តើត្រូវផ្អែកលើតម្លៃប្រតិបត្តិការពីអ្នកជំនាញអចលនវត្ថុឬទេ?

⇒ ភាគហ៊ុន

# (4) ការកំណត់កាតព្វកិច្ច

Rule

- ក្នុងករណីដែលមើលឃើញច្បាស់ថាកាតព្វកិច្ចមានច្រើនជាងទ្រព្យសកម្ម យើងអាចធ្វើនីតិវិធីបោះបង់សន្តតិកម្មភ្លាមៗ (ម១២៦០) ឬ ការយល់ព្រមដោយមានកម្រិត (ម១២៥៦) (ជាគោលការណ៍អំឡុងពេលនៃការយល់ព្រម ឬការបោះបង់ គឺមានអំឡុងពេល៣ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្ដើម - ម១២៤៨ ក១)។

# ចំណុចពិភាក្សានៃការអនុវត្តជាក់ស្តែង(1) (អំឡុងពេលនៃបោះបង់ និង ការយល់ព្រមដោយមានកម្រិត)

- ការបោះបង់ និង ការយល់ព្រមដោយមានកម្រិតនៃសន្តតិកម្ម ជាគោលការណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ៣ខែគិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ប៉ុន្តែពេលខ្លះរយៈពេល ៣ខែនេះមានផលលំបាក ដោយហេតុថាមត៌កនៅដាច់ឆ្ងាយពីគ្នាខ្លាំងជាដើម។ ហេតុនេះមានករណីពិសេសនៃអំឡុងពេល។
  - ការពន្យាពេលដោយតុលាការ (ម១២៤៨ ក១ វា២)
  - ករណីពិសេសដែលសន្តតិជនទទួលមរណភាព (ម១២៤៩)
  - ករណីពិសេសក្នុងករណីអនីតិជន (ម១២៥០)
  - ករណីពិសេសដែលមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ច (ម១២៥១)